00369293



**Declassified to Public**
**06 September 2012**

# យុត្តិធម៌សម្រាប់ចាមម៉ូស្លីមក្រោមកម្ពុជាប្រជាធិបតេយ្យ

**អ៊ីសា ឧស្មាន់** (Ysa Osman)

*សៀវភៅឯកសារលេខ២ មជ្ឈមណ្ឌលឯកសារកម្ពុជា*

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
ម៉ោង (Time/Heure) : 31-Aug-2009, 09:38
Chanthan Phok

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
31-Aug-2009
Chanthan Phok

Original EN: 00274986-00274999

## អ៊ុកគូបាស់ (Oukoubah)

ស្មាន់ ស្លេស(Sman Sleh) ហៅ សុខា(Sokha), រ៉ូន ម៉ាត់(Roun Math) ហៅ រ៉ូន សាវី(Roun Savy), សា ម៉ាត់(Sa Math) ហៅ សាវឿន(Savoeun) និងម៉ាន តិច(Man Tech)

៤-៧

ស្មាន់ ស្លេស(Sman Sleh) រ៉ូន ម៉ាត់(Roun Math) សា ម៉ាត់(Sa Math) និង ម៉ាន តិច (Man Tech) បានស្គាល់គ្នាតាំងពីក្មេងម្ល៉េះ។ អ្នកទាំងបីដំបូង បានរស់នៅជាមួយគ្នានៅភូមិ ពោធិ៍ទន្លេក្រោម(Po Tole Kraom) ហើយម៉ាន តិច(Man Tech) រស់នៅក្បែរភូមិចាមលើ[116]។ អ្នកទាំងបួននាក់បានចូលទាហានខ្មែរក្រហម ហើយត្រូវបានចាប់ខ្លួនដាច់ដោយឡែកពីគ្នា។ ឋិតក្រោមការសួរចម្លើយ ម្នាក់ៗបានសារភាពថាក្បត់ ហើយបីនាក់ក្នុងចំណោមបុរសទាំងនេះមានការជាប់ពាក់ព័ន្ធជាមួយអ្នកផ្សេងពីម្នាក់ ឬច្រើននាក់។ អ្នកទាំងបួនត្រូវបានគេបញ្ជូនទៅកាន់មន្ទីរស-២១ ហើយក្រោយមកត្រូវបានគេសម្លាប់ចោល[117]។

---

[116] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ៖

រ៉ូន ណុប(Roun Nop)អាយុ៥៥ឆ្នាំ បងស្រីរបស់ រ៉ូន ម៉ាត់(Roun Math) នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុក កោះធំ ខេត្តកណ្ដាល ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩។

ឡាស់ សារាស់(Lah Sarah) អាយុ៤៨ឆ្នាំ ប្អូនថ្លៃស្រីរបស់ សា ម៉ាត់(Sa Math) ភូមិចាមលើ ឃុំព្រែកថ្មី ស្រុក កោះធំ ខេត្តកណ្ដាល ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

ស្មាន់ ណុប(Sman Nop)អាយុ៦៧ឆ្នាំ បងស្រីរបស់ស្មាន់ ស្លេស(Sman Sleh) នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុក កោះធំ ខេត្តកណ្ដាល ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

ម៉ាត់ ដុឡាស់(Math Dullah) មិត្តភ័ក្តិរបស់ម៉ាន តិច(Man Tech) ដូចបានរៀបរាប់ខាងលើ។

ភូមិចាមលើឋិតនៅឆ្លងទន្លេពីភូមិពោធិ៍ទន្លេក្រោម។

[117] លិខិតជាច្រើនរបស់ខ្មែរក្រហម ដែលរក្សាទុកនៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រៀបរាប់អំពីការដឹកជញ្ជូនមនុស្សពីអង្គភាពផ្សេងៗទៅកាន់មន្ទីរស-២១ (ទួលស្លែង)។ ឧទា. នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧ ម៉ែន(Men) នៅកងពលលេខ៥០២ បានសរសេរលិខិតមួយច្បាប់បញ្ជូនមនុស្សទៅឱ្យឌុច(Duch)ថា៖ "នៅល្ងាចថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំបានបញ្ជូនពួកក្បត់ចំនួន២៧នាក់ដែលជាប់ខ្សែប្រឆាំងក្នុងកងពល៣១០ និង៤៥០។ នៅម៉ោង៧ ឬ៨ល្ងាចនេះ គេស្នើឱ្យខ្ញុំបញ្ជូនបួននាក់ទៀតដែលជាប់ខ្សែនឹង២៥នាក់មុន។ នៅម៉ោង១០ ឬ១១យប់នេះ ខ្ញុំបានបញ្ជូនខ្សែរបស់ម៉ៅ(Mao) និងខ្សែមុត(Muth)បន្ថែម៧នាក់ទៀត។ ម្សិលមិញបងបាននិយាយថា [ខ្ញុំអាច]យកចម្លើយសារភាពចម្លងមួយច្បាប់របស់ម៉ៅ(Mao) ហើយបើសិនអង្គការមិនជំទាស់ទេ ខ្ញុំសូមស្នើសុំឯកសារប្រើប្រាស់ក្នុងការស្វែងរកខ្មាំងផ្សេងទៀត"។ នៅថ្ងៃទី

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧១ នៅអាយុ១៦ឆ្នាំ ស្មាន់ ស្លេះ(Sman Sleh) បានធ្វើទាហានខ្មែរក្រហម ហើយក្នុងឆ្នាំ១៩៧៥ គាត់ត្រូវបានគេចាត់តាំងឲ្យទៅអង្គភាព៩៩ នៃកងពលលេខ៧០៣ មានមូលដ្ឋាននៅតាខ្មៅ(Ta Khmau)[118]។ មុនឆ្នាំ១៩៧១ គាត់និងម្តាយរបស់គាត់បានរស់នៅក្នុងភូមិពោធិ៍ទន្លេក្រោម(Po Tole Kraom) ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល។ ឪពុករបស់គាត់ឈ្មោះ ស្មាន់(Sman)បានស្លាប់ក្នុងសម័យសង្គមរាស្ត្រនិយម ហើយម្តាយរបស់គាត់ឈ្មោះ ម៉ាស់(Mah) បានស្លាប់បន្ទាប់ពីឆ្នាំ១៩៧៩។ បងប្អូនបង្កើតដែលនៅរស់ទាំងបួននាក់របស់គាត់ រស់នៅក្នុងភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល[119]។

មុនឆ្នាំ១៩៧៣ រ៉ួន ម៉ាត់(Roun Math) បានជួយរកត្រីឪពុកម្តាយរបស់គាត់នៅភូមិពោធិ៍ទន្លេក្រោម។ គាត់បានធ្វើទាហានខ្មែរក្រហមនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៣ នៅអាយុ១៩ឆ្នាំ ហើយគឺជាយុទ្ធជននៅក្នុងអនុសេនាតូច៧៣២ កងអនុសេនាធំ៧៣ កងវរសេនាតូច១១៧ នៃកងពលធំលេខ៧០៣[120]។ នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៤ ម៉ាត់(Math)បានធ្វើការឲ្យទុំ(Tum) ប្រធានមន្ទីរ១៣ ហើយបានទៅនៅមន្ទីរ០៤ ក្នុងខែមេសា ឆ្នាំ១៩៧៥។ គាត់បានទទួលការហ្វឹកហ្វឺនជាអ្នកបើកបរនៅមន្ទីរ៩០ក្នុងខែឧសភា ឆ្នាំ១៩៧៥ ហើយបានធ្វើការនៅក្នុងសមត្ថកិច្ចមន្ទីរពាណិជ្ជកម្មរដ្ឋ ចាប់ផ្តើមក្នុងខែមិថុនានៃឆ្នាំនោះ។ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ ម៉ាត់(Math)ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់គុក៤៣[121]។

---

៣ ខែមេសា ឆ្នាំ១៩៧៧ សាន(San)នៅកងពលលេខ៣១០បានសរសេរទៅកាន់ឌុច(Duch)ថា៖ "ស្នើប្រគល់មនុស្ស៧នាក់ទៅឲ្យសមមិត្ត។ ដូចបងណាត(Nath)បានសម្រេច។ ដូច្នេះសូមទទួលយកពួកវា..."។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ កំពង់ផែនៅកំពង់សោម បានផ្ញើលិខិតមួយច្បាប់ឲ្យឌុច(Duch)ថា៖ "ថ្ងៃនេះ យើងសូមស្នើបញ្ជូនវ៉ាង(Vang)ទៅឲ្យសមមិត្ត"។

[118] *ចម្លើយសារភាពរបស់ស្មាន់ ស្លេះ(Sam Sleh)* មជ្ឈមណ្ឌលឯកសារកម្ពុជា លេខសៀវភៅបញ្ជីរាយឈ្មោះ D0២៦៨៥។

[119] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ស្មាន់ ណុប(Sman Nop) ដូចបានរៀបរាប់ខាងលើ។

[120] *ចម្លើយសារភាពរបស់ស្មាន់ ស្លេះ(Sman Sleh) ដូចបានរៀបរាបខាងលើ។*

បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយហ៊ឹម ហ៊ុយ(Him Huy) ភូមិអន្លង់សាន្ត ឃុំព្រែកស្តី ស្រុកកោះធំ ខេត្ត កណ្តាល ថ្ងៃទី៤ ខែមករា ឆ្នាំ២០០២។

[121] *ចម្លើយសារភាពរបស់ រ៉ួន ម៉ាត់(Roun Math)* មជ្ឈមណ្ឌលឯកសារកម្ពុជា សៀវភៅបញ្ជីរាយឈ្មោះលេខD0២៦៧៤

ឪពុកម្តាយរបស់គាត់ឈ្មោះ សុប រ៉ូន(Sop Roun) និង លី ជីប(Ly Chip) បានស្លាប់នៅក្នុងជំនាន់ប៉ុលពត។ សព្វថ្ងៃបងប្អូនបង្កើតរបស់គាត់រស់នៅភូមិចាមលើ[122]។

សា ម៉ាត់(Sa Math)រស់នៅជាមួយឪពុកម្តាយរបស់គាត់ អែល សា(El sa)និង ស(Sor)នៅភូមិពោទន្លេក្រោម។ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ នៅអាយុ១៧ឆ្នាំ គាត់បានធ្វើទាហានខ្មែរក្រហមនៅក្នុងកងអង្គភាព៩៩ នៃកងពលធំលេខ៧០៣[123]។ បងប្អូនបង្កើតរបស់គាត់ទាំងបួននាក់សព្វថ្ងៃ រស់នៅភូមិចាមលើ[124]។

មុនពេលគាត់ធ្វើទាហានខ្មែរក្រហមមុនឆ្នាំ១៩៧៥ ម៉ាន តិច(Man Tech)បានរស់នៅភូមិចាមលើ។ ក្នុងខែមីនា ឆ្នាំ១៩៧៥ នៅអាយុ២៣ឆ្នាំ តិច(Tech)នៅជាមួយមន្ទីរ០៥[125]។ សព្វថ្ងៃឪពុកម្តាយនិងបងប្អូនបង្កើតរបស់គាត់រស់នៅភូមិចាមលើ[126]។

## ការចាប់ខ្លួន

ស្មាន់ ស្លេស(Sman Sleh) ត្រូវបានចាប់ខ្លួននៅម៉ោង៨:៣០យប់ ក្នុងខែកក្កដា ឆ្នាំ១៩៧៥ នៅឯប៉ុស្តិ៍យោធាខ្មែរក្រហមមួយ ក្បែរវត្តក្រពើហា ក្នុងស្រុកតាខ្មៅ ខេត្តកណ្តាល។ គេមិនអាចដឹងអំពីប្រភព ដែលនិយាយថាតើស្លេស(Sleh) ត្រូវបានឃុំខ្លួនក្នុងគុកមួយផ្សេងទៀត មុនពេលបញ្ជូនខ្លួនទៅមន្ទីរស-២១នោះទេ។ ចម្លើយសារភាពរបស់គាត់មិនត្រូវបានកត់ត្រាទុកដោយអ្នកសួរចម្លើយនៃមន្ទីរស-២១នោះទេ នៅពេលដែលកំណត់ហេតុជាបន្តបន្ទាប់ឃើញមាននៅលើរឹមទំព័រខាងលើនោះថា៖ "ឯកភាពឲ្យដឹកទៅកាន់មន្ទីរម-២១ ឬមន្ទីរ២១ ដោយសារការជាប់ពាក់ព័ន្ធជាច្រើនជាមួយបណ្តាញ ដែលធ្វើឲ្យលេចចេញនូវគំនិតថា ឪពុកម្តាយ និងបងប្អូនបង្កើតរបស់គាត់ មានការជាប់ពាក់ព័ន្ធជាមួយចាម"។

---

[122] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ រ៉ូន ណុប(Roun Nop) ដូចបានរៀបរាប់ខាងលើ។

[123] *ចម្លើយសារភាពរបស់ សា ម៉ាត់(Sa Math)* មជ្ឈមណ្ឌលឯកសារកម្ពុជា សៀវភៅបញ្ជីរាយឈ្មោះលេខ D0២៦៧៦។

[124] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ រ៉ូន អាឌីកាស់ (Roun Adikah)អាយុ៤១ឆ្នាំ បងថ្លៃស្រីរបស់ សា ម៉ាត់(Sa Math) នៅភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

[125] *ប្រវត្តិផ្ទាល់ខ្លួនរបស់ម៉ាន តិច(Man Tech)* មជ្ឈមណ្ឌលឯកសារកម្ពុជា សៀវភៅបញ្ជីរាយឈ្មោះលេខD0២៦១៤។

[126] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ម៉ាត់ ដុឡាស់(Math Dullah) ដូចបានរៀបរាប់ខាងលើ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៥[127]។ កំណត់ហេតុនេះបង្ហាញថា នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៥ ស្មាន់ ស្លេះ(Sman Sleh) ត្រូវបានគេបញ្ជូនពីគុកមិនស្គាល់អត្តសញ្ញាណទៅកាន់មន្ទីរស-២១។

សមមិត្តនៃទាហានខ្មែរក្រហមម្នាក់ឈ្មោះ ស្លេះ លី(Sleh Ly)បានរំលឹកអំពីការចាប់ខ្លួន ស្មាន់ ស្លេះ(Sman Sleh)ថា៖ "ក្នុងអំឡុងពេលនៃល្ងាចមួយក្នុងខែកក្កដា ឆ្នាំ១៩៧៥ នៅម៉ោងប្រហែល៨:៣០យប់ ខ្លួនខ្ញុំ ស្មាន់ ស្លេះ(Sman Sleh) និងសា ម៉ាត់(Sa Math) កំពុងដេកនៅក្នុងមុងជាមួយគ្នាក្នុងផ្ទះមួយខាងលិចវត្តក្រពើហា។ ខ្ទមដំបូលប្រក់ស័ង្កសីមួយ។ ខ្ញុំបានឃើញមនុស្សពីប្រាំឬប្រាំមួយនាក់ស្លៀកពាក់ខ្មៅ ជាមួយនឹងក្រម៉ាបង់ក កាន់កាំភ្លើងគ្រប់ដៃ។ ពួកវាបានហៅមេក្រុមឲ្យចេញក្រៅផ្ទះ។ នៅក្នុងផ្ទះនោះមានមនុស្សចំនួន១២នាក់។ ពួកវាបានចាប់ ស្មាន់ ស្លេះ(Sman Sleh) ចេញពីមុង (អ្នកដេកជាមួយខ្ញុំផងដែរ) ហើយយកចេញទៅខាងក្រៅទ្វារ។ ខ្ញុំបានឃើញពួកវាធាក់ក្បាល ស្មាន់ ស្លេះ(Sman Sleh) ហើយបោះចូលទៅក្នុងឡានមួយ" លី(Ly) បន្តទៀតថា "ខ្ញុំបានឃើញយ៉ាងច្បាស់...ហើយគេមិនត្រឹមតែចាប់ខ្លួនស្មាន់ ស្លេះ(Sman Sleh)ប៉ុណ្ណោះទេ ប៉ុន្តែខ្មែរចំនួនប្រាំនាក់ទៀតក៏ត្រូវចាប់ខ្លួនដែរ"។ ស្លេះ លី(Sleh Ly)បានបន្តថា "បន្ទាប់ពីចាប់ខ្លួនហើយ មេបញ្ជាការកងអង្គភាពបានហៅអ្នកគ្រប់គ្នាប្រជុំ ហើយបានប្រាប់ពួកយើងមិនឲ្យដឹកនាំការប្រឆាំង ហើយរត់ត្រឡប់ទៅផ្ទះវិញនោះទេ។ ប៉ុន្តែតាមពិតយើងដឹងទាំងអស់គ្នាថា គ្មានអ្នកណាដឹកនាំអ្នកណាឲ្យធ្វើអ្វីមួយនោះទេ ពីព្រោះវាពិតជាពិបាកខ្លាំងណាស់នៅកន្លែងនោះ"[128]។

រ៉ូន ម៉ាត់(Roun Math)ត្រូវបានចាប់ខ្លួននៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ពីអង្គភាពដឹកជញ្ជូនពាណិជ្ជកម្មរដ្ឋ ជាកន្លែងដែលគាត់ធ្វើការជាអ្នកបើកឡានដឹកជញ្ជូនផ្គត់ផ្គង់សម្ភារៈទៅឲ្យមន្ទីរផ្សេងៗ។ ចម្លើយសារភាពរបស់គាត់បង្ហាញថា ទីតាំងចតរថយន្តសម្រាប់អង្គភាពរបស់គាត់ឋិតនៅ "ទួលគោកចម្ងាយ៥០ម៉ែត្រប៉ែកខាងត្បូងអង់តែនទូរទស្សន៍" ហើយរថយន្តរបស់គាត់គឺជា "រថយន្តរបស់ចិនមានកង់បួន"។ បន្ទាប់ពីគាត់ត្រូវចាប់ខ្លួនភ្លាម ម៉ាត់(Math)ត្រូវបានគេឃុំខ្លួននៅក្នុងមន្ទីរ៤៣[129] ហើយ

---

[127] *ចម្លើយសារភាពរបស់ស្មាន់ ស្លេះ(Sman Sleh)* ដូចបានរៀបរាប់ខាងលើ។

[128] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ស្លេះ លី(Sleh Ly) អាយុ៤២ឆ្នាំ អតីតទាហានខ្មែរក្រហមជាមួយ ស្មាន់ ស្លេះ (Sman Sleh) និង សា ម៉ាត(Sa Mat) នៅភូមិ ស្លាប ឡេង(Slap Leng) ឃុំស្វាយ រុំពា ស្រុកបរសេត ខេត្តកំពង់ស្ពឺ ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០០។

[129] *ចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math)* ដូចបានរៀបរាប់ខាងលើ។

ក្រោយមកត្រូវបានគេផ្ទេរទៅកាន់មន្ទីរស-២១។ ទោះបីថ្ងៃនៃការផ្ទេរគាត់ទៅកាន់មន្ទីរស-២១មិនច្បាស់ក៏ដោយ ក៏មានកំណត់ហេតុមួយពីអ្នកត្រួតពិនិត្យឯកសារលើចម្លើយសារភាពរបស់ម៉ាត់(Math) នៅមន្ទីរស-២១សរសេរថា "ឯកភាពឲ្យដាក់គុក" ចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ ហើយកំណត់ហេតុមួយទៀតសរសេរថា "សុំការបំភ្លឺ" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៦[130] បង្ហាញថា ម៉ាត់(Math)បានមកដល់មន្ទីរស-នៅថ្ងៃ ឬមុនថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ ហើយត្រូវបានបានគេឃុំខ្លួននៅទីនោះនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៦។

សុស មីន(Soh Min)បានរំលឹករឿងរ៉ាវអំពីការចាប់ខ្លួន រ៉ួន ម៉ាត់(Roun Math)។ ខណៈដែលគាត់និងអ្នកផ្សេងទៀតកំពុងកាន់ឥវ៉ាន់នៅឯតាខ្មៅ មានមិត្តម្នាក់របស់ រ៉ួន ម៉ាត់ (Roun Math) បានខ្សឹមប្រាប់ មីន(Min)ថា៖ "រ៉ួន ម៉ាត់(Roun Math)បានបើកឡានរបស់គាត់ទៅកាន់បង្គោលភ្លើងមួយ ហើយពួក[ខ្មែរក្រហម]បានដាក់គុកគាត់"។ មីន(Min)បានមិនអាចចាំឈ្មោះអ្នកដែលប្រាប់គាត់នោះបាន[131]។

រ៉ួន ណុប(Roun Nop) បងស្រីរបស់ រ៉ួន ម៉ាត់(Roun Math)បាននិយាយថា៖ "ប្អូនប្រុសរបស់គាត់ ម៉ាត់(Math) ត្រូវបានពួកខ្មែរក្រហមយកទៅធ្វើទាហាន។ គាត់បានទៅប្រហែលមួយខែ ហើយកាលគាត់ឈឺ ហើយនៅឯមន្ទីរពេទ្យ (ខ្ញុំចាំឈ្មោះពេទ្យនោះមិនបាន) ម្តាយឪពុករបស់ខ្ញុំបានស្នើសុំគាត់ [ប្រធានពេទ្យ] ដើម្បីអនុញ្ញាតឲ្យប្អូនប្រុសខ្ញុំសម្រាកនៅផ្ទះ និងដើម្បីមើលគ្រូខ្មែរផងដែរ។ នៅពេលគាត់បានគ្រាន់បើបន្តិច មេបញ្ជាការទាហានបានមកយកគាត់ត្រឡប់ទៅវិញ។ លើកនេះគាត់បានគេចខ្លួនត្រឡប់មកផ្ទះវិញម្តងទៀតបានប្រាំថ្ងៃ ប៉ុន្តែគេបានមកតាមគាត់ ហើយគាត់បានរត់ទៅភូមិពោ ទន្លេ (Po Tonle)ជាកន្លែងដែលប្រធានភូមិឈ្មោះ ហ៊ឹម លេស(Him Leh) បានជួយលាក់គាត់។ ម៉ាត់(Math)នៅឯ ពោ ទន្លេ អស់រយៈពេលប្រហែលបីខែ នៅពេលដែលគេបានចាប់គាត់យកទៅធ្វើទាហានម្តងទៀត។ ក្នុងឆ្នាំ១៩៧៥ គាត់បានគេចខ្លួនត្រឡប់មកផ្ទះវិញម្តងទៀត បន្ទាប់មកគេបានយកគាត់ទៅអង្គភាពម្តងទៀត ចាប់តាំងពីពេលនោះមក បាត់ដំណឹងឈឹង"[132]។

---

[130] ដូចបានរៀបរាប់រួចមកហើយ។

[131] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ សុស មីន(Soh Min) អាយុ៤៤ឆ្នាំ អតីតទាហានខ្មែរក្រហម នៅភូមិហនុម៉ាន (Hanuman) ឃុំកាន់ដឹង(Kandoeng) ស្រុកបាទី ខេត្តតាកែវ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០០។

[132] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ រ៉ួន ណុប(Roun Nop) ដូចបានរៀបរាប់ខាងលើ។

សា ម៉ាត់(Sa Math) ត្រូវបានចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ១៩៧៥[133]។ ទោះបី ស្លេស លី(Sleh Ly) និង សា ម៉ាត់(Sa Math) បាននៅជាមួយគ្នានៅល្ងាចចាប់ខ្លួន ស្មាន់ ស្លេស(Sman Sleh) ក៏ដោយ ក៏លី(Ly)មិនបានដឹងអំពីការចាប់ខ្លួន ម៉ាត់(Math)ទេ៖ ស្លេស លី(Sleh Ly)បាននិយាយថា៖ "បន្ទាប់ពីការចាប់ខ្លួន ស្មាន់ ស្លេស (Sman Sleh) គេ[មេបញ្ជាអង្គភាព]បានបំបែក សា ម៉ាត់(Sa Math) និងខ្លួនខ្ញុំ ហើយម៉ាន តិច (Man Tech)ត្រូវបានបែកគ្នាចាប់ពីពេលដែលយើងបានទៅដល់កោះខ្សាច់ទន្លេ"[134]។

ចម្លើយសារភាពរបស់ម៉ាត់(Math) និយាយថា គាត់ត្រូវបានចាប់ខ្លួនពីអង្គភាព៩៩នៃកងពលធំលេខ៧០៣ យកទៅ"តាខ្មៅ" (មិនមានការបញ្ជាក់ណាមួយទាក់ទងនឹងមុខតំណែងពិតប្រាកដនោះទេ) ហើយត្រូវបានឃុំខ្លួន នៅក្នុងមន្ទីរអប់រំកែប្រែរបស់កងពល[135]។ ចម្លើយសារភាពរបស់គាត់ និយាយ

---

[133] *ចម្លើយសារភាពរបស់ សា ម៉ាត់(Sa Math)* ដូចបានរៀបរាប់ខាងលើ។

[134] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ស្លេស លី(Sleh Ly) ដូចបានរៀបរាប់ខាងលើ។

[135] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ មុយ តិច ឡេង(Muy Tech Leng)អាយុ៤៧ឆ្នាំ នៅភូមិបារេនក្រោម(Baren Kraom) និងម៉ៅ ណិល(Mao Nil)អាយុ៤៧ឆ្នាំ អតីតទាហានខ្មែរក្រហម កងពលធំលេខ៧០៣ នៅភូមិ៨ ក្នុងឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០។ ឡេង(Leng) និង ណិល(Nil)បានបង្ហាញថា កងពលធំលេខ៧០៣ មានការទទួលខុសត្រូវសំខាន់ជាងកងពលធំផ្សេងទៀត ហើយមានការទុកចិត្តពីបក្សកុម្មុយនិស្តកម្ពុជា។ កងពលធំនេះ ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៧១ជាកងពលធំលេខ១២ ដែលក្រោយមកបានក្លាយទៅជាកងពលធំលេខ៧០៣ ហើយដំបូងធ្វើប្រតិបត្តិការនៅក្នុងស្រុកកោះធំ និងជាផ្នែកមួយរបស់ស្រុកស្អាង។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងពលធំនេះមានបេសកកម្មការពារភ្នំពេញ។ បុរសទាំងពីរនាក់នោះបានពន្យល់ថា នៅដើមឆ្នាំ១៩៧៥ កងពលធំនេះឋិតក្រោមបញ្ជារបស់ ណាត (Nath) និងភិន(Pin)។ ស៊ឹម ម៉ែល(Sim Mel) ហៅ ម៉ាន(Man) (បុរសជនជាតិចាមម្នាក់ ដែលបានជាប់គុកនៅមន្ទីរស-២១)គឺជាអ្នកនាំសាររបស់ ណាត(Nath)។ ឡេង(Leng)និងណិល(Nil) មិនបានដឹងអំពីការផ្លាស់ប្តូរនៅខាងក្នុងកងពលធំលេខ៧០៣នេះទេបន្ទាប់ពីឆ្នាំ១៩៧៥មក ចាប់តាំងពីពួកគេត្រូវបានបញ្ជូនទៅកាន់ព្រំដែនវៀតណាមមក។

បទសម្ភាសន៍របស់ អៀ ម៉េង ទ្រី(Ea Meng Try)ជាមួយ ជៀម សឿ(Cheam Soeu)ហៅ សឿ(Soeu)អាយុ៣៨ឆ្នាំ អតីតទាហានកងពលធំលេខ៧០៣ នៅភូមិសាពោ(Sapor) ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០០។ សឿ(Soeu)បាននិយាយថា "កងពលធំលេខ៧០៣ មានបេសកកម្មការពារបរិវេណក្រុងភ្នំពេញ ជាពិសេស នៅតាមចំណុចសំខាន់ៗ ដូចជា មន្ទីរស-២១ ស្ថានមន្ទីរវង្ស ទួលទំពូង និងបឹងត្របែក"។

បទសម្ភាសន៍របស់ អៀ ម៉េង ទ្រី(Ea Meng Try)ជាមួយថ្លុង ឡា(Thlong La)អាយុ៣៨ឆ្នាំ អតីតទាហាននៅកងពលធំលេខ៥០២របស់កម្ពុជាប្រជាធិបតេយ្យ នៅភូមិក្រាំងល្វា ឃុំអញ្ចាញរូង(Anhchanh Roung) ស្រុកបរិបូណ៍

ថា៖ “ធ្វើនៅថ្ងៃទី១៧ ខែ១១ ឆ្នាំ១៩៧៦ នៅមន្ទីរអប់រំកែប្រែ៧០៣”[136] ជាកន្លែងដែលនួន ជា (Nuon Chea)ទទួលបន្ទុក[137]។ ក្រោយមកម៉ាត់(Math)ត្រូវបានបញ្ជូនទៅមន្ទីរស-២១។

ម៉ាន តិច(Man Tech) គឺជាមនុស្សចុងក្រោយដែលត្រូវចាប់ខ្លួននៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៧៨ នៅមន្ទីរ ខ(Kho) (ហៅ មន្ទីរ២៤)។ មានឯកសារខ្មែរក្រហមជាច្រើនបង្ហាញថា ខ(Kho)គឺជាសាខារបស់មន្ទីរស-[138]។ ប្រធាន ខ(Kho)នៃមន្ទីរស-២១គឺ ហ៊ុយ(Huy)[139] ដែលជូនកាលកម្ពា

ខេត្តកំពង់ឆ្នាំង ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០០។ គាត់បាននិយាយថា កងពលធំចំនួនពីរនៅភ្នំពេញមានបេសកកម្មសន្តិសុខនៅក្នុងទីក្រុងគឺកងពលធំទី៥០២ និងកងពលធំទី៧០៣។ ឡា(La)បាននិយាយថា មេបញ្ជាការនៃកងពលធំទី៥០២គឺសមមិត្ត ធី (Thy)។

[136] *ចម្លើយសារភាពរបស់ សា ម៉ាត់(Sa Math)* ដូចបានរៀបរាប់ខាងលើ។

[137] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ៊ឹម ហ៊ុយ(Him Huy) ដូចបានរៀបរាប់ខាងលើ។ នួន ជានេះ មិនមែនជាលេខារងនៃបក្សកុម្មុយនិស្តកម្ពុជាទេ។

[138] សៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា “មានសាខាមន្ទីរស-២១ពីរផ្សេងទៀត។ មួយ មន្ទីរស-២១ ខ(Kha) មានទីតាំងឋិតនៅតាខ្មៅ ខេត្តកណ្តាល ភាគខាងត្បូងភ្នំពេញ។ ទីពីរ មន្ទីរស-២១ ខ(Kho) មានទីតាំងនៅព្រៃស [គុកចាស់សម័យអាណានិគមបារាំង] ឋិតនៅប៉ែកខាងលិចទីក្រុងភ្នំពេញ ក្នុងខណ្ឌដង្កោ ក្រុងភ្នំពេញ ដែលគេស្គាល់ថាជាមន្ទីរ២៤ផងដែរ ហើយត្រូវបានគេប្រើប្រាស់ជាជំរំអប់រំកែប្រែមួយ។ លើសពីនេះទៅទៀត មន្ទីរស-២១ ខ(Kho) មានបេសកកម្មផ្គត់ផ្គង់ស្បៀងឲ្យមន្ទីរស-២១”។

បញ្ជីឈ្មោះអ្នកទោស ដែលត្រូវសម្លាប់នៃមន្ទីរស-២១ជាច្រើន នៅក្នុងបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញ អំពីទំនាក់ទំនងរវាងមន្ទីរស-២១ និងមន្ទីរស-២១ ខ(Kho)។ ឧទាហរណ៍ បញ្ជីឈ្មោះអ្នកទោសដែលត្រូវសម្លាប់នៃមន្ទីរស-២១មួយមានចុះហត្ថលេខាដោយតំណាងមន្ទីរស-២១ឈ្មោះ ហរ(Hor) នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧ កត់សំគាល់ថា “បញ្ជីឈ្មោះអ្នកទោសដែល [ត្រូវកម្ទេច] ផ្នែករបស់បង ហ៊ុយ ស្រែ(Huy Sre)” មានន័យថា អ្នកទោសមកពីមន្ទីរស-២១ ខ(Kho) (ហ៊ុយ ស្រែ)។ បញ្ជីឈ្មោះក៏បង្ហាញផងដែរថា ហរ(Hor) បានបញ្ជាឲ្យសម្លាប់អ្នកទោសចំនួន១៨នាក់ និងកូនក្មេង១៦០នាក់ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧។

*ចម្លើយសារភាពរបស់ ស៊ីម ម៉ែល(Sim Mel) ហៅ ម៉ាន(Man)* សៀវភៅបញ្ជីរាយឈ្មោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលេខ D0២៦៧៨ កត់សំគាល់ថា ម៉ែល(Mel) ត្រូវបានគេបញ្ជូនពីមន្ទីរស-២១ទៅធ្វើស្រែនៅមន្ទីរ២៤ (មន្ទីរស-២១ ឃ(Khor)។

[139] ហ៊ុយ(Huy) (ឬ ហ៊ុយ ស្រែ(Huy Sre) គឺជាប្រធានមន្ទីរស-២១ ខ(Kho) ឬមន្ទីរ២៤។ ឈ្មោះដើម ណាន់ ហ៊ុយ (Nan Huy) គាត់កើតនៅខែមីនា ឆ្នាំ១៩៥១ នៅភូមិទន្លេបាទី ស្រុកបាទី ខេត្តតាកែវ។ ហ៊ុយ(Huy)ចូលបដិវត្តនៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧០។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ហ៊ុយ(Huy)គឺជាកសិករ។ ប្រពន្ធរបស់គាត់ឈ្មោះ ប្រុក សាមុត (Prok Samuth) (ហៅ ប្រុក ខឿន(Prok Khoeun) កើតនៅក្នុងឆ្នាំ១៩៥៣ នៅភូមិរំចេក ឃុំត្នោត ស្រុកបាទី ខេត្ត

ភិបាលខ្មែរក្រហមគេស្គាល់ថា ហ៊ុយ ស្រែ(Huy Sre) ឯចំណែកមន្ទីរស-២១ត្រូវបានបញ្ជាដោយឌុច (Duch)[140]។ មុនពេលចាប់ខ្លួន តិច(Tech)គឺជាយុទ្ធជននេសាទនៅមន្ទីរ២៤ (មន្ទីរស-២១ ខ(Kho))។

---

តាកែវ។ គាត់ចូលបដិវត្តនៅខែមីនា ឆ្នាំ១៩៧២។ ក្នុង១៩៧៧ បក្សបានដក ប្រុក ខឿន(Prok Khoeun) ចេញពីមន្ទីរយោធាទៅកាន់មន្ទីរស-២១។ ឪពុករបស់ហ៊ុយ(Huy)ឈ្មោះ នន់ រស់(Nun Ros) ហើយម្ដាយរបស់គាត់ឈ្មោះ អែល ណាន(El Nan) ពួកគាត់រស់នៅទន្លេបាទី។ *ប្រវត្តិផ្ទាល់ខ្លួនរបស់ ប្រុក ខឿន(Prok Khoeun)* ឆ្នាំ១៩៧៧ សៀវភៅបញ្ជីរាយឈ្មោះលេខ K០៨២៧៣។

បញ្ជីឈ្មោះអ្នកទោសដែលត្រូវសម្លាប់ជាច្រើននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានចុះហត្ថលេខាដោយ ហ៊ុយ ស្រែ(Huy Sre)។ ឧទាហរណ៍ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៧ គាត់បានបញ្ជាឲ្យសម្លាប់អ្នកទោសចំនួន២១នាក់។ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧ ហ៊ុយ(Huy)បានចុះហត្ថលេខាលើបញ្ជីឈ្មោះចំនួនពីរនៃអ្នកទោសដែលត្រូវសម្លាប់។ បញ្ជីឈ្មោះទីមួយមានឈ្មោះអ្នកទោសចំនួន១៨នាក់ និងសេចក្ដីថារណ៍ពន្យល់ថា "ស្នើឲ្យសួរចម្លើយអ្នកទោសតែបួននាក់ប៉ុណ្ណោះ ហើយអ្នកទោសដែលនៅសល់ត្រូវកម្ទេចចោល"។ បញ្ជីឈ្មោះទីពីរមានឈ្មោះអ្នកទោសស្រីមានផ្ទៃពោះចំនួន១១នាក់ ហើយកូនក្មេងអត់មានឈ្មោះមួយចំនួន។

កម្មាភិបាលខ្មែរក្រហមម្នាក់ផ្សេងទៀតក៏មានឈ្មោះថា ហ៊ុយ(Huy)ដែរ (ឈ្មោះដើម យូ ហ៊ុយ(You Huy សព្វថ្ងៃ ហ៊ឹម ហ៊ុយ(Him Huy)។ គាត់កើតនៅក្នុងឆ្នាំ១៩៥៤នៅភូមិក្បាលជ្រោយ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល។ គាត់ចូលបដិវត្តនៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧២ ហើយធ្វើជាទាហាន ជាមេផ្នែក តំណាងមេក្រុម និងជាមេបញ្ជាការកងអនុសេនាធំ ហើយក្រោយមកទទួលខុសត្រូវចំពោះអង្គភាពការពារនៅមន្ទីរស-២១។ ឪពុករបស់ហ៊ុយ(Huy)ឈ្មោះ យូ ហ៊ឹម (You Him) និងម្ដាយរបស់គាត់ឈ្មោះ សៀម ជើ(Seam Cheu)។ គាត់មានបងប្អូនចំនួនប្រាំបីនាក់។ *ប្រវត្តិផ្ទាល់ខ្លួនរបស់ យូ ហ៊ុយ(You Huy)* ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ សៀវភៅបញ្ជីរាយឈ្មោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ D០០០១៦។ សព្វថ្ងៃ ហ៊ុយ(Huy)រស់នៅភូមិអន្លង់សាន្ត ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល។

[140] ឌុច(Duch) ហៅ កាំង ហ្កេក អ៊ាវ ឬខៀវ(Khiev) កើតក្នុងឆ្នាំ១៩៤២ ទោះបីអត្តសញ្ញាប័ណ្ណរបស់គាត់បញ្ជាក់ថា គាត់កើតនៅក្នុងឆ្នាំ១៩៤៣ក៏ដោយ។ ឪពុករបស់គាត់គឺជាជនជាតិវៀតណាម ហើយម្ដាយរបស់គាត់កាត់ចិន។ ពួកគេរស់នៅស្រុកស្ទោង ខេត្តកំពង់ធំ។ ឌុច(Duch)ជានិច្ចជាកាលពូកែខាងគណិតវិទ្យានៅក្នុងថ្នាក់របស់គាត់ ហើយជាប់លេខមួយនៅក្នុងការប្រលងថ្នាក់ជាតិផ្នែកគណិតវិទ្យា។ ក្នុងឆ្នាំ១៩៦១ គាត់បានសិក្សា បាក់ I។ ក្នុងអំឡុងឆ្នាំ១៩៦៤-១៩៦៥ គាត់បានបង្ហាត់រូបវិទ្យា គីមីវិទ្យា គណិតវិទ្យា និងអក្សរសាស្ត្រខ្មែរនៅឯសាលាមួយក្នុងស្រុកស្គន់ ខេត្តកំពង់ចាម។

ក្នុងឆ្នាំ១៩៦៦ ឌុច(Duch)ត្រូវបានចាប់ខ្លួន ហើយជាប់គុករហូតដល់ឆ្នាំ១៩៧០ នៅពេលលន់ នល់(Lon Nol) ឡើងកាន់អំណាច ហើយដោះលែងអ្នកទោសទាំងអស់នៅក្នុងប្រទេស។ ឌុច(Duch)បន្ទាប់មកបានទៅរស់នៅវត្តឧណ្ណាលោម ជាកន្លែងដែលគាត់បានបង្រៀនម្ដងទៀត។ ក្នុងអំឡុងពេលនេះ គាត់ត្រូវបានគេស្គាល់ជាមេដឹកនាំខ្មែរក្រហមម្នាក់។ គាត់ជិតស្និទ្ធនឹងសុក ធួក(Sok Thuok) ហៅ វ៉ន វេត(Vorn Vet) និងខៀវ សំផន។ គ្រូរបស់គាត់នៅវត្តឧណ្ណាលោមដែលស្និទ្ធនឹងសម្ដេចព្រះសង្ឃរាជ ជួន ណាត បានប្រាប់ឌុច(Duch)ថា "កុំចូលក្នុងនយោបាយ"។ ឌុច(Duch)បានឆ្លើយថា "លោតា ធ្វើនយោបាយដើម្បីរំដោះប្រជាជន ដើម្បីជួយប្រជាជន"។ ក្នុងឆ្នាំ១៩៧៣ គាត់បានចេញទៅលាក់ខ្លួនក្នុងព្រៃ

ដោយនាំប្រជាជនក្មេងៗពីវត្តឧណ្ណាលោមទៅជាមួយជាច្រើននាក់។ (បទសម្ភាសន៍របស់ ផាត កុសល(Phat Kosal) និង វ៉ាន់ ថន ពៅតារា(Vanthan Peou Dara) ជាមួយគឹម សួរ(Kim Sour) អតីតនិស្សិតរបស់ឌុច(Duch) និងលៀម សារុណ(Leam Sarun) អតីតមិត្តភក្តិជិតស្និទ្ធរបស់ឌុច(Duch) ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩)។

ឌុច(Duch)ត្រូវបានគេស្គាល់ថាជាមនុស្សនិយាយលេងច្រើន មិនមែនជាមនុស្សសាហាវឃោរឃៅទេ។ គាត់មិនចូលចិត្តប្រកែកគ្នាទេ ហើយប្រសិនបើអ្នកណាម្នាក់កាន់តែជេរគាត់ គាត់កាន់តែញញឹម។ គាត់ជាមនុស្សជិតស្និទ្ធនឹងសិស្សរបស់គាត់ ដែលស្រលាញ់ចូលចិត្តគាត់ ហើយមិនលេងល្បែងទេ លេងស្រី ឬផឹកទេ (ប៉ុន្តែគាត់ជក់បន្តកន្ទុយគ្នា)។

ក្នុងឆ្នាំ១៩៧១ ឌុច(Duch)បានក្លាយជាប្រធានមន្ទីរ១៣ ក្នុងភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលក្រោយមកឋិតនៅក្នុងតំបន់រំដោះមួយ។ របាយការណ៍លេខ៦៥/៧៥ លេខចេញផ្សាយ១៨នៃ*សាធារណៈរដ្ឋខ្មែរ* ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៥ (សៀវភៅបញ្ជីរាយឈ្មោះនៃមជ្ឈមណ្ឌលឯកសារកម្ពុជាលេខL00៥៦២) និយាយអំពី “មន្ទីរឃុំឃាំងអមលាំង”ជាមួយឌុច(Duch)ជាប្រធាន ហើយចាន់(Chan)ជាអនុប្រធាន៖ “អ្នកទាំងពីរសាហាវឃោរឃៅណាស់”។ ឧទាហរណ៍ អតីតអ្នកទោសម្នាក់នៅមន្ទីរ១៣ បានបំភ្លឺថា មានអ្នកទោសម្នាក់ឈ្មោះ សុន(Son) ត្រូវបានដុតដោយចន្លុះនៅទីនោះ ហើយបន្ទាប់មកសម្រក់ជ័រដាក់ពេញខ្លួនប្រាណរបស់គាត់។ បទសម្ភាសន៍របស់ វ៉ាន ថន ពៅដារា(Vanthan Peou Dara)ជាមួយ ហាម អ៊ីម(Ham Im) នៅភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២00១ ក្នុង*ការស្វែងរកការពិត* លេខ២២ ខែតុលា ឆ្នាំ២00១ ទំព័រ២១-២៤។

មន្ទីរ១៣ត្រូវបានបែកខ្ញែកបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយឌុច(Duch) និងអនុប្រធានរបស់គាត់ រួមជាមួយនឹងកម្មាភិបាលផ្សេងទៀត ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅឯមន្ទីរឃុំឃាំងទើបបង្កើតថ្មីក្នុងទីក្រុងភ្នំពេញ។ បានរៀបរាប់រួចហើយ។ ឌុច(Duch)ត្រូវបានគេឲ្យធ្វើជាប្រធាននៃមន្ទីរនេះ ដែលមានឈ្មោះថាមន្ទីរស-២១។ ខណៈពេលនៅទីនោះ គាត់បានអាន និង/ឬ បានចុះហត្ថលេខាលើចម្លើយសារភាពរាប់ពាន់ ហើយបានចេញបញ្ជាឲ្យតាមដាន និងសួរចម្លើយ។ កំណត់ហេតុដើមដំបូងបំផុតត្រូវបានគេជឿថាសរសេរដោយឌុច(Duch)គឺជាចម្លើយសារភាពរបស់ កែ ឆាង (Ke Chhang) ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៧៥ ជាចម្លើយសារភាពដែលឌុច(Duch)បានសរសេរថា៖ “ចាត់វិធានការនយោបាយ ហើយប្រុងប្រយ័ត្នជាប់ជានិច្ច កុំឲ្យវាស្លាប់ ធ្វើទារុណកម្មវាក្នុងរបៀបមួយកុំឲ្យមានស្លាកស្នាម”។ ពីរថ្ងៃក្រោយមក ឌុច(Duch) បានសរសេរថា៖ “ចាត់វិធានការទារុណកម្មឲ្យបានធ្ងន់ពីព្រោះសម្រេច១00%ថា វាមានឋានន្តរសក្តិរវាងសក្តិពីរ និងសក្តិបី វាជាគិញយូរហើយ”។ ចម្លើយសារភាពរបស់ កែ ឆាង(Ke Chhang) ជាជាងឡាននិងជាងរថភ្លើង ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ TSL K-១២៥។ កេ ឆាង(Ke Chhang) ត្រូវបានសម្លាប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៥។ ចម្លើយសារភាពរបស់ញ៉េប ឌីម(Nhep Dim)ហៅ អ៊ុង ឆន(Ong Chhorn) អាយុ៥៣ឆ្នាំ ថ្ងៃទី៣0 ខែសីហា ឆ្នាំ១៩៧៥ ក៏មានអក្សរសរសេរដៃដូចប៉ះបិទនឹងអក្សរសរសេរដៃរបស់ឌុច(Duch)ដែរគឺ៖ “អាមួយគួរឲ្យស្អប់ខ្ពើមនេះចចេសខ្លាំងណាស់ វ៉ៃវាទាល់តែវាសន្លប់”។ ឯកសារទាក់ទងនឹងឌុច(Duch) សៀវភៅបញ្ជីរាយឈ្មោះTSLលេខ N-២១២។

ឌុច(Duch)ក៏មានការជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មនេះដែរ។ គេជឿថា កំណត់ហេតុមួយដែលសរសេរដោយគាត់ ឃើញមាននៅលើចម្លើយសារភាពរបស់ស្ត្រីម្នាក់ឈ្មោះ ព្រុំ សំនៀង(Prum Sam Nieng)៖ “ម្នាក់គួរឲ្យស្អប់

បន្ទាប់ពីការចាប់ខ្លួន គាត់ត្រូវបានគេផ្ទេរទៅកាន់ "ផ្ទះលេខ៣១ បន្ទប់ធំលេខ៤ បន្ទប់តូចលេខ១"ក្នុងមន្ទីរស-២១[141]។

## ចម្លើយសារភាព

ចម្លើយសារភាពរបស់អ្នកទាំងបួននាក់ត្រូវបានគេរកឃើញនៅសារៈមន្ទីរទួលស្លែង (ចម្លើយសារភាពរបស់ ស្មាន់ ស្លេះ(Sman Sleh) និងសា ម៉ាត់(Sa Math)មិនត្រូវបានធ្វើនៅក្នុងមន្ទីរស-២១ទេ ប៉ុន្តែត្រូវបានគេបញ្ជូនជាមួយគ្នាទៅមន្ទីរស-២១)។ ចម្លើយសារភាពរបស់ ស្មាន់ ស្លេះ(Sman Sleh) មាន៦ទំព័រ ចម្លើយសារភាព រ៉ូន ម៉ាត់ (Roun Math)មាន៧៤ទំព័រ និងចម្លើយសារភាពរបស់ សា ម៉ាត់(Sa Math)មាន៨ទំព័រ។ ចម្លើយសារភាពរបស់ តិច(Tech)មានតែប្រវត្តិផ្ទាល់ខ្លួនមួយទំព័រប៉ុណ្ណោះ តាមពិតមិនមែនជាចម្លើយសារភាពទេ។ តារាងខាងក្រោមបង្ហាញអំពី "ខ្មែរក្បត់" ម្នាក់ៗសុទ្ធតែត្រូវបានគេអះអាង រួមទាំងមិត្តភក្តិរបស់ពួកគេពីភូមិ និងសមមិត្តយោធាខ្មែរក្រហមផងដែរ។

---

ខ្ចើមនេះនិយាយចេញមកតិចណាស់! មិនចាំបាច់សង្ខេបខ្លីទេ! ខ្ញុំមិនបានពន្យល់អ្វីទេ ខ្ញុំវ៉ៃវានឹងខ្សែតីចំនួន៣០ ហើយរុញវាឱ្យសរសេរម្តងទៀត។ ម្នាក់នេះធ្វើមិនបានល្អសោះនៅពេលនេះ"។ សៀវភៅបញ្ជីរាយឈ្មោះTSLលេខP-១៥៣។

មានលិខិតជាច្រើនពីអង្គភាពទាំងឡាយដែលប្រគល់អ្នកទោសទៅឱ្យឌុច(Duch)។ ឧទាហរណ៍ លិខិតមួយពីកងវរសេនាតូចលេខ៤១៤ និយាយថា៖ "ជូនចំពោះសមមិត្តឌុច(Duch)៖ ស្នើសុំប្រគល់១៧នាក់ទៅឱ្យសមមិត្ត សូមសមមិត្តទទួលយក ពួកវាបានចូលCIAទាំងអស់ យោងតាមចម្លើយសារភាពរបស់ មើន ខាន(Meun Khan) ដែលបានបញ្ជូននៅថ្ងៃទី២៦ ខែ៤ ឆ្នាំ១៩៧៧"។ សៀវភៅបញ្ជីរាយឈ្មោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលេខ D0១០៧៨។

កំណត់ហេតុចុងក្រោយដែលគេស្គាល់ ត្រូវបានសរសេរ និងចុះហត្ថលេខាដោយឌុច(Duch) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨។ កំណត់ហេតុនោះឃើញមាននៅលើចម្លើយសារភាពរបស់អ្នកទោសម្នាក់ឈ្មោះ គឹម សុក(Kim Sok)៖ "បងជាទីគោរព បញ្ហានៃការលាក់ជនជាតិវៀតណាមបានកើតឡើងនៅក្នុងតំបន់២៥ ហើយជាប់ទាក់ទងនឹងឪពុករបស់ អៀង (Eang) (ឪពុករបស់ហ៊ុយ(Huy))។ មនុស្សសំខាន់ដែលបានចាកចេញគឺ ទ្រីញ(Tring)។ តាមដានសមកម្មភាពរបស់វា។ ខ្ញុំសូមស្នើថា ខ្ញុំនឹងមិនទុកម្នាក់នេះយូរទេ។ នៅពេលខ្ញុំដឹងពីសកម្មភាពរបស់វាភ្លាម ខ្ញុំនឹងទាក់ទង ខ្ញុំសូមស្នើថា ខ្ញុំយកវាទៅសម្លាប់"។ ចម្លើយសារភាពរបស់ គឹម សុក (Kim Sok) ប្រធានអង្គភាព១១ មន្ទីរ២៤ សៀវភៅបញ្ជីរាយឈ្មោះនៃ TSL លេខK-៣៤៦។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ឌុច(Duch)បានគេចខ្លួនពីទីក្រុងភ្នំពេញ។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយសព្វថ្ងៃឋិតនៅក្នុងគុកយោធាមួយរងចាំការជំនុំជម្រះ។

[141] *ប្រវត្តិផ្ទាល់ខ្លួនរបស់ ម៉ាន តិច(Man Tech)* ដូចបានរៀបរាប់ខាងលើ។

| | មិត្តភក្តិជាប់ពាក់ព័ន្ធ | "អ្នកសមគំនិត" ផ្សេងទៀត<br>ឈ្មោះអ្នកដែលនៅរស់មិតក្នុងអក្សរដិតក្រាស់<br>ឈ្មោះមានផ្កាយ* ត្រូវបានសម្ភាសន៍សម្រាប់ការសិក្សានេះ | | |
|---|---|---|---|---|
| រ៉ូន ម៉ាត់(Roun Math) | ស្មាន់ ស្លេស(Sman Sleh) | **កាលី ហាក់***(Kaly Hak) | ស្រេន ម៉ាន(Sren Man) | ម៉ាត់ សិត(Math Set) |
| | សា ម៉ាត់(Sa Math) | សា ហ៊ីម(Sa Him) | មីត មីន(Mit Min) | សម(Sam) |
| | ម៉ាន តិច(Man Tech) | កែ(Kae) | **សុស មីន*(Soh Min)** | សាន(San) |
| | | សុស កែ(Soh Kae) | រៀស(Rieh) | **លី ត្រិច(Ly Trech)** |
| | | **ហ៊ីម កែ(Him Kae)*** | សា (Sa) | ទុំ(Tum) |
| | | កូប លេស(Kaup Leh) | សា រ៉ូន(Sa Roun) | តាហឺ សាហ្វី អេ(Taheu Safi E) |
| | | សា លីម(Sa Lim) | ស្លេស(Sleh) | **លី យូ(Ly You)** |
| | | **ស្លេស លី(Sleh Ly)*** | ស្លេស សាន(Sleh San) | យ៉ា សុស(Ya Soh) |
| ស្មាន់ ស្លេស(Sman Sleh) | រ៉ូន ម៉ាត់(Roun Math) | ឈ្លាញ(Chhlaunh) | អឿន(Oeun) | **ធុប វន(Top Vorn)*** |
| | ម៉ាន តិច(Man Tech) | អេង(Eng) | ហេង អឿន(Heng Oeun) | ទ្រី(Try) |
| | | សេង គីម(Seng Kim) | ប្រុស(Pros) | ទុំ(Tum) |
| | | គួយ(Kuoy) | គីម ពុធ(Kim Put) | ទុយ(Tuy) |
| | | **ជីវ លី(Chiev Ly)** | ម៉ាត់ សិត(Math Set) | ហួ វាត(Huo Vat) |
| | | ម៉ាត់(Math) | សឿន(Soeun) | សែន យ៉ា(Sen Ya) |
| | | មុត(Muth) | ស្រី ធៀប(Srei Thiep) | |
| សា ម៉ាត់(Sa Math) | រ៉ូន ម៉ាត់(Sa Math) | ហៀង(Heang) | លី ម៉ាន(Ly Man) | |
| | ម៉ាន តិច(Man Tech) | **ស្លេស លី(Sleh Ly)*** | សិត(Set) | |
| | ស្មាន់ ស្លេស(Sman Sleh) | | វុធ(Vuth) | |
| ម៉ាន តិច(Man Tech) | -- | -- | -- | -- |

យ៉ាងហោចណាស់មាន៨នាក់ក្នុងបញ្ជី បានរួចពីស្លាប់ពីរបបខ្មែរក្រហម ប្រាំនាក់ត្រូវបានធ្វើសម្ភាសន៍សម្រាប់ការសិក្សានេះ[142]។ នៅពេលបានសួរអំពីសកម្មភាពរបស់ពួកគេប្រឆាំងនឹងពួកខ្មែរ

[142] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ៖

ហ៊ីម លេស(Him Leh) ខ្សែរបស់ រ៉ូន ម៉ាត់(Roun Math) ដូចបានរៀបរាប់ខាងលើ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៨៩។

កាលី ហាក់(Kaly Hak) អាយុ៥៥ឆ្នាំ ខ្សែរបស់ រ៉ូន ម៉ាត់(Roun Math) ភូមិចាមលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៨៩។

ក្រហមដូចបានរៀបរាប់ក្នុងចម្លើយសារភាព អ្នកខ្លះមិនអាចចងចាំអ្វីៗដែលពួកគាត់បានធ្វើនៅក្នុងការប្រឆាំងនោះទេ ឯអ្នកខ្លះទៀតបានទទួលស្គាល់ថា ខ្លួនលួចប្រឆាំងនឹងខ្មែរក្រហម។ ពួកគេទាំងអស់គ្នាមានការភ្ញាក់ផ្អើល ហើយអួតអាងពីការសប្បាយរបស់ខ្លួន ដែលបានរួចពីស្លាប់ក្នុងរបបខ្មែរក្រហម ទោះបីជាឈ្មោះរបស់ពួកគេបានទៅដល់មន្ទីរស-២១ក៏ដោយ។ អ្នកដែលបានរួចពីស្លាប់ប្រហែលជាបានធ្វើដូច្នេះ ពីព្រោះពួកខ្មែរក្រហមមានការភាន់ច្រឡំលើឈ្មោះចាម ដែលមានការពិបាកក្នុងការបញ្ចេញសម្លេង និងសរសេរជាភាសាខ្មែរ[143]

ស្មាន់ ស្លេស(Sman Sleh) បានសរសេរថា៖ "ខ្ញុំ ម៉ាត់ សិត(Math Set) តិច(Tech) [ម៉ាន តិច(Man Tech)] និង សារី [រ៉ូន ម៉ាត់(Roun Math)] បានជួបគ្នានៅលើទូកមួយកណ្តាលស្ទឹង។ សិត(Set)បាននិយាយថា វាងាយស្រួលរត់ទៅប្រទេសវៀតណាម ស្រណុកស្រួល ម្ហូបឆ្ងាញ់ មានប្រាក់ខែ ដែលជាគោលបំណងនៃការធ្វើជាទាហានរបស់យើង ធ្វើបដិវត្តគឺលំបាកខ្លាំងណាស់"។ ស្លេស(Sleh)បានសរសេរបន្ថែមទៀតថា គាត់មានផែនការសម្លាត់មួយពី ទុំ(Tum) ប្រធានមន្ទីរ១៣ ដូច រ៉ូន ម៉ាត់ អញ្ចឹងដែរ។ "ទុំ(Tum)បានប្រាប់ខ្ញុំឲ្យរៀបចំបើកការបាញ់ប្រហារក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៥ ហើយនឹងមានកម្លាំងពីខាងក្រៅមកបង្ហាញខ្លួននៅតាខ្មៅ"[144]។

ចម្លើយសារភាពរបស់ស្លេស(Sleh) មានឈ្មោះ ថុប វ៉ន(Top Vorn) ក្នុងបញ្ជី ជាទាហានខ្មែរក្រហម ជាខ្សែប្រឆាំងមួយ ដោយរៀបរាប់ថា វ៉ន(Vorn)គឺជាមេដឹកនាំម្នាក់ដែលញុះញង់ឲ្យមានការប្រឆាំងនៅឯមន្ទីរពេទ្យ ដោយនិយាយថា៖ "ក្នុងអំឡុងពេលនៃការវាយប្រហារនៅលើផ្លូវជាតិលេខ

---

ថុប វ៉ន(Top Vorn) អាយុ៥០ឆ្នាំ ខ្សែរបស់ស្មាន់ ស្លេស(Sman Sleh) ភូមិ៨ ឃុំពោធិបាន ស្រុកកោះធំ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

ស្លេស លី(Sleh Ly) ខ្សែរបស់ រ៉ូន ម៉ាត់(Roun Math) និង សា ម៉ាត់(Sa Math) ដូចបានរៀបរាប់ខាងលើ។

សុស មីន(Soh Min)អាយុ៤៤ឆ្នាំ ខ្សែរបស់ រ៉ូន ម៉ាត់(Roun Math) ដូចបានរៀបរាប់ខាងលើ។

[143] សាម៉ាន កាជី(Saman Kaji)បានរំលឹកថា "ពួកវាបានហៅឈ្មោះអ្នកគ្រប់គ្នាខុស។ ឈ្មោះរបស់ខ្ញុំគឺ ជី(Ji) ពួកវាហៅ ចី(Chi) ដូច្នេះខ្ញុំបានប្រាប់ពួកវាថា ខ្ញុំឈ្មោះ ជី(Ji) មិនមែនជីក(Chik)ទេ"។ បទសម្ភាសន៍របស់ យុ ឆាំង ជាមួយ ស្មាន់ កាជី(Sman Kaji) ដូចបានរៀបរាប់ខាងលើ។

"ពួកវា[ខ្មែរក្រហម]បានហៅឈ្មោះខ្ញុំខុសថា "ម៉ាក់ ជី(Mak Chi)"ប៉ុន្តែឈ្មោះខ្ញុំ ម៉ាន ចិត(Man Jet)"។ បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ អាប់ឌុល ម៉ាចិត ប៊ីន អាប់ឌុលឡាស់(Abdul Majet bin Abdullah) ដូចបានរៀបរាប់ខាងលើ។

[144] *ចម្លើយសារភាពរបស់ស្មាន់ ស្លេស(Sman Sleh)* ដូចបានរៀបរាប់ខាងលើ។

២១ ខ្ញុំត្រូវរបួសហើយបញ្ជូនទៅកាន់មន្ទីរពេទ្យ [មិនបានបញ្ជាក់ឈ្មោះមន្ទីរពេទ្យ]។ នៅក្នុងមន្ទីរពេទ្យនោះ វ៉ន(Vorn) បានប្រាប់ខ្ញុំថា...គាត់ដេកពេទ្យដោយសារគាត់បាញ់ខ្លួនឯងចំដៃ។ គាត់បានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំខ្លាច ខ្ញុំគួរតែបាញ់ខ្លួនឯង ហើយនៅខាងក្រោយ គាត់បានជំរុញឲ្យខ្ញុំប្រាប់ទាហានផ្សេងៗទៀតឲ្យបាញ់ខ្លួនឯង"[145]។ ប៉ុន្តែ វ៉ន(Vorn) បានប្រាប់រឿងខុសគ្នា។ គាត់ស្ទើរតែមិនអាចចាំ ស្លេស(Sleh)បាន (ឡេង សុខា(Leng Sokha)) ដោយនិយាយថា ដំបូងពួកគេបានជួបគ្នានៅមន្ទីរពេទ្យ២៤ នៅភូមិព្រែកតាគោក(Prek Ta Kork)។ វ៉ន(Vorn)បាននិយាយថា "ក្នុងអំឡុងពេលប្រហែលឆ្នាំ១៩៧៣ ខ្ញុំសម្រាកនៅមន្ទីរពេទ្យព្រែកតាគោក(Prek Ta Kork)(ក្នុងស្អាង) ដោយសារខ្ញុំបាញ់កាំភ្លើងយន្តនិងដោយសារធ្វេសប្រហែលរបស់ខ្ញុំ ខ្ញុំត្រូវរបួសចំដៃ។ ខណៈពេលនៅឯមន្ទីរពេទ្យ ខ្ញុំបានឃើញមនុស្សម្នាក់ឈ្មោះ សុខា(Sokha) [ស្មាន់ ស្លេស]។ ខ្ញុំបានឃើញជើងរបស់គាត់រុំប៉ង់ស៊ីម៉ង់ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ត្រូវរបួសចំកន្លែងណាទេ ពីព្រោះរបួសរបស់គាត់ត្រូវបានសំអាតនៅកន្លែងផ្សេងមួយទៀត។ ខ្ញុំមិនអាចចាំបានថាតើជើងឆ្វេង ឬជើងស្តាំទេ។ ខ្ញុំបានជួប ឡេង សុខា(Leng Sokha)អស់រយៈប្រហែល១០ថ្ងៃ។ ចំណែកឪពុកម្តាយនិងក្រុមគ្រួសាររបស់គាត់វិញ ខ្ញុំមិនដឹងពីទីកន្លែងកំណើតរបស់ពួកគេទេ"[146]។

គាត់ក៏បានបដិសេធណែនាំ ឬញុះញង់ ស្លេស(Sleh)ផងដែរ៖ "ខ្ញុំហាននិយាយបានថា របួសរបស់ខ្ញុំគឺកើតឡើងដោយចៃដន្យទេ។ ប្រសិនបើអ្នកលោកមិនជឿខ្ញុំទេ ទៅសួរនារសាខ្ញុំទៅ។ គាត់នៅរស់នៅឡើយ"។ វ៉ន(Vorn)បានបន្ថែមថា "ខ្ញុំមិនដែលស្គាល់ឈ្មោះ សុខា (Sokha)នោះទេ[មិនមានទំនាក់ទំនងអីជាមួយគាត់ទេ] ខ្ញុំបានជួបគាត់តែនៅក្នុងមន្ទីរពេទ្យប៉ុណ្ណោះ។ តើខ្ញុំអាចញុះញង់គាត់យ៉ាងដូចម្តេចទៅ? ខ្ញុំមិនបាននិយាយអ្វីប្រឆាំងនឹងអ្នកណាម្នាក់ទេ ខ្ញុំគ្រាន់តែប្រាប់ឲ្យយុវជនរៀបចំស្មារតីប្រយុទ្ធរបស់ពួកគេតែប៉ុណ្ណោះ"[147]។

ឡាច ម៉ៅ(Lach Mao) បានផ្តល់ព័ត៌មានមួយចំនួនទាក់ទងនឹង ស្លេស(Sleh)។ អតីតអ្នកទោសខ្មែរក្រហមម្នាក់នៅមន្ទីរ១៥ គាត់បានស្គាល់ចាមម្នាក់ឈ្មោះ ម៉ាត់(Math) ខណៈពេលដែលពួកគេជាប់គុកទាំងអស់គ្នា។ "យើងទាំងអស់គ្នារងនូវការឈឺចាប់ខ្លាំងណាស់ នៅពេលដែលគេវ៉ៃយើង

[145] ដូចបានរៀបរាប់រួចមកហើយ។

[146] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ថុប វ៉ន(Top Vorn) ដូចបានរៀបរាប់ខាងលើ។

[147] ដូចបានរៀបរាប់រួចមកហើយ។

យកយើងទៅសម្លាប់ចោល ឬធ្វើទុក្ខបុកម្នេញយើងទាំងថ្ងៃទាំងយប់។ ដោយគ្មានការភ័យខ្លាច ម៉ាត់(Math) បាននិយាយថា ដំបូងគាត់នឹងទៅប្រទេសវៀតណាម ហើយបើសិនជាគាត់ទទួលបានជោគជ័យ គាត់នឹងត្រឡប់មកយកពួកយើងវិញ...មានអ្នកទោសចំនួន ៥៥នាក់នៅមន្ទីរ១៥"។ ម៉ៅ(Mao)ក៏បាននិយាយផងដែរថា "បន្ទាប់ពីម៉ាត់(Math) បានចាកចេញពីមន្ទីរអស់រយៈពេលប្រហែលជាមួយសប្តាហ៍ ខ្មែរក្រហមចាប់គាត់បាននៅព្រែកជ្រៃ(Prek Chrey) ក្នុងស្រុកកោះធំ ហើយបានបញ្ជូនគាត់ត្រឡប់ទៅកាន់មន្ទីរ១៥វិញដើម្បីសម្លាប់"[148]។ ឈ្មោះ ម៉ាត់(Math) ឃើញមាននៅលើចម្លើយសារភាពរបស់ ស្លេស(Sleh) ដោយបានជំរុញ ស្លេស(Sleh)ឲ្យរត់ចេញទៅប្រទេសវៀតណាម។

ចម្លើយសារភាពរបស់ រ៉ូន ម៉ាត់( Roun Math) បាននិយាយថា "ខ្ញុំចូលបដិវត្តនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៣ ដោយមានការណែនាំពី អែល ហ៊ឹម(El Him) ប្រធានភូមិចាមលើ...នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៣ បន្ទាប់ពីខ្ញុំនៅឯមន្ទីរពេទ្យព្រែកតាដន(Prek Ta Don)អស់រយៈពេល២៥ថ្ងៃ ខ្ញុំបានគេចខ្លួនត្រឡប់មកផ្ទះវិញ។ នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៤ ខ្ញុំបានទៅជាមួយ ទុំ(Tum) ប្រធានមន្ទីរ១៣ ហើយទុំ(Tum)បានឲ្យខ្ញុំត្រឡប់មកផ្ទះវិញ។ ក្នុងអំឡុងពេលខែកក្កដា ឆ្នាំ១៩៧៤ ខ្ញុំបានរស់នៅជាមួយ ហ៊ឹម លេស(Him Leh) ប្រធានភូមិពោទន្លេក្រោម។ ក្នុងខែមករា ឆ្នាំ១៩៧៥ ខ្ញុំបានចូលបដិវត្តវិញ ដែលមានការណែនាំពី សាលេស ហ៊ឹម(Saleh Him) អនុប្រធានភូមិពោទន្លេក្រោម។ ក្នុងខែមីនា ឆ្នាំ១៩៧៥ ពួកយើងប្រាំនាក់បានរត់ចេញត្រឡប់មកផ្ទះវិញ"។ ទាក់ទងនឹងការស្នាក់នៅរបស់គាត់នៅពេទ្យព្រែកតាដន(Prek Ta Don)នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៣ គាត់បានសរសេរថា៖ "កាលខ្ញុំនៅអង្គភាព១១៧ [អង្គភាពដែលគាត់បានចូលនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៣] នៅសមរភូមិមុខព្រែកជ្រៃ ខ្ញុំបានរៀបចំវាយប្រហារខ្មាំង គ្រាប់១០៥មីលីម៉ែត្របានត្រូវលេណដ្ឋានខ្ញុំ ហើយខ្ញុំបានដួល។ ស្មារតីរបស់ខ្ញុំមានការចុះខ្សោយបន្តិច។ ក្រោយមកខ្មាំងបានបាញ់គ្រាប់M៧២មីលីម៉ែត្រ ធ្វើឲ្យជំហររបស់ខ្ញុំដួលម្តងទៀត។ ខ្ញុំពិតជាខូចស្មារតីយ៉ាងពិតប្រាកដនៅពេលនោះ។ អង្គការបានបញ្ជូនខ្ញុំ ទៅព្យាបាលនៅមន្ទីរព្រែកតាដន(Prek Ta Don)។ នៅពេលខ្ញុំបានជាសះស្បើយ ខ្ញុំបានរត់ទៅផ្ទះ"[149]។

---

[148] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ឡាច ម៉ៅ(Lach Mao) អាយុ៤៥ឆ្នាំ អតីតអ្នកទោសខ្មែរក្រហមនៅមន្ទីរ១៥ ភូមិ៨ ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

[149] *ចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math)* ដូចបានរៀបរាប់ខាងលើ។

រ៉ូន ម៉ាត់(Roun Math) មានច្រើនណាស់ដែលត្រូវនិយាយអំពីសកម្មភាពប្រឆាំងរបស់គាត់៖ “បន្ទាប់ពីទទួលបានការណែនាំ និងការចាត់តាំងពី ហ៊ីម លេស(Him Leh) អស់រយៈពេលបីថ្ងៃ នៅម៉ោង៨:០០ល្ងាច [ថ្ងៃមួយ]ក្នុងអំឡុងខែមិថុនា ឆ្នាំ១៩៧៤ ខ្ញុំបាននាំ ម៉ាត់ សិត(Math Set) ឡេង សុខា(Leng Sokha) [ស្មាន់ ស្លេស(Sman Sleh)] ម៉ាន តិច(Man Tech) និង សា ម៉ាត់(Sa Math) មកជួបជុំគ្នានៅកណ្តាលស្ទឹង។ ខ្ញុំបានណែនាំពួកគេទាំងអស់ថា ប្រសិនបើយើងខ្លាចសមរភូមិ ជៀសវាងសមរភូមិមុខ យើងត្រូវធ្វើតាម ហ៊ីម លេស(Him Leh)។ គាត់ចង់ឲ្យយើងចូលទៅក្នុងចំណោមប្រជាជន ហើយញុះញង់ពួកគេឲ្យស្អប់ខ្ពើមសមាជិកគណៈឃុំឈ្មោះ ហេង សុស(Heng Soh) [រៀវ សុស(Riev Soh)] និង ម៉ាត់(Math) ហើយញុះញង់ប្រជាជនទាំងនោះឲ្យរត់ចេញទៅវៀតណាម។ ហើយ គាត់ [ហ៊ីម លេស(Him Leh)]បាននិយាយថា ចំពោះល្បិចកលនៃការចលនាប្រជាជន គាត់នឹងឲ្យទូកមួយសំណាញ់មួយ។ អ្នកទាំងបួននាក់បានយល់ស្របជាមួយខ្ញុំ”។ គាត់បានសរសេរអំពីផែនការប្រឆាំងមួយទៀតថា “នៅពេលខ្ញុំយកស្រូវអង្ករទៅតាខ្មៅ ខ្ញុំបានជួប [ប្រធានមន្ទីរ១៣]ក្នុងអំឡុងខែឧសភា ឆ្នាំ១៩៧៥។ ទុំ(Tum)បានប្រាប់ខ្ញុំអំពីផែនការហែរក្បួនបាតុកម្មទៅកាន់ទីក្រុងភ្នំពេញក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៥ ហើយគាត់ចង់ឲ្យខ្ញុំរង់ចាំក្បួនបាតុកម្មនៅតាខ្មៅ”[150]។ យោងតាម ហ៊ីម ហ៊ុយ(Him Huy) ប្រធានតំបន់២៥ បុរសម្នាក់ឈ្មោះ តា សុក(Ta Sok) បានដឹកនាំក្បួនបាតុកម្មមួយឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ ហើយក្រោយមកត្រូវបានចាប់ខ្លួន[151]។

ហ៊ីម លេស(Him Leh) គឺជាប្រធានភូមិពោទន្លេក្រោមរបស់ខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧១-១៩៧៤។ គាត់បានឆ្លើយតបទៅនឹងការទទួលខុសត្រូវរបស់ ម៉ាត់(Math) ដោយនិយាយថា ខ្មែរក្រហម បានបញ្ជាឲ្យគាត់ចាប់ប្រជាជនក្មេងៗ បង្ខំពួកគេឲ្យចូលធ្វើទាហាន ប៉ុន្តែគាត់មិនបានធ្វើការងារចាត់តាំងនោះទេ។ គាត់បានយល់ស្របជាមួយចម្លើយសារភាព រ៉ូន ម៉ាត់(Roun Math)ថា “នៅពេលនោះខ្លួនគាត់ និងប្រជាជនមានការមិនពេញចិត្តនឹងអង្គការ ពួកគេបានធ្វើទុក្ខបុកម្នេញយុវជនឲ្យចូលធ្វើទាហាន ហើយនៅពេលពួកគេគេចខ្លួនត្រឡប់មកផ្ទះវិញ ពួកគេត្រូវបានចាប់ខ្លួន ដាក់គុក ហើយធ្វើបាបគ្រប់មធ្យោបាយ។ កាលនោះខ្ញុំបានឲ្យយុវជនវាយប្រហារ រៀវ សុស(Riev Soh) សមាជិកម្នាក់នៃគណៈឃុំព្រែកថ្មី ពីព្រោះបើសិនយុវជនចាមណាម្នាក់រត់គេចខ្លួនពីការធ្វើទាហាន គាត់

---

[150] ដូចបានរៀបរាប់រួចមកហើយ។

[151] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ៊ីម ហ៊ុយ(Him Huy) ដូចបានរៀបរាប់ខាងលើ ថ្ងៃទី៤ ខែមករា ឆ្នាំ២០០២។

ចាប់បាន គាត់នឹងវ៉ៃពួកគេ ហើយបញ្ជូនទៅដាក់គុក។ ហើយ[គាត់]បានបញ្ជាឲ្យ *hakem* បិទព្រះវិហារចោល"។ លេស(Leh)ក៏បាននិយាយផងដែរថា "នៅពេលនោះ ខ្ញុំបានបញ្ជាមនុស្សប្រហែល១០នាក់ឲ្យយកសំណាញ់មួយ និងទូកមួយទៅនេសាទនៅព្រែកស្តី នេសាទជាការបិទបាំងមួយដើម្បីរកផ្លូវចេញទៅវៀតណាម។ ប៉ុន្តែចេញទៅមិនរួច ដោយហេតុថា រៀវ សុស(Riev Soh)បានរកឃើញផ្លូវមុន" លេស(Leh)បានពន្យល់ថា "រ៉ូន ម៉ាត់(Roun Math) និងម៉ាន តិច(Man Tech) គឺជាមនុស្សឋិតក្នុងចំណោមមនុស្ស១០នោះ។ ខ្ញុំមិនអាចចងចាំអ្នកផ្សេងទៀតបានទេ"[152]។

ចម្លើយសារភាព រ៉ូន ម៉ាត់(Roun Math)បាននិយាយថា "ហ៊ឹម ហ៊ុយ(Him Huy) បានទទួលផែនការប្រឆាំងមួយពី ទុំ(Tum) ប្រធានមន្ទីរ១៣" ប៉ុន្តែ លេស(Leh)បានបដិសេធផែនការនេះ ដោយនិយាយថា "ខ្ញុំមិនដែលស្គាល់ ទុំ(Tum)ទេ... ប្រជាជននិងខ្ញុំខ្លួនឯងមិនមានការពេញចិត្តនឹងអង្គការទេ។ គ្មានអ្នកណាម្នាក់បានបញ្ជាផែនការនេះទេ ខ្ញុំបានធ្វើរឿងរ៉ាវទាំងអស់នេះដោយគំនិតផ្តួចផ្តើមរបស់ខ្ញុំ "[153]។

កាលី ហាក់(Kaly Hak)គឺជាប្រធានយុវជននៅភូមិពោធន្លេពីឆ្នាំ១៩៧១-១៩៧៣។ យោងតាមចម្លើយសារភាព រ៉ូន ម៉ាត់(Roun Math)ថា "កាលី ហាក់(Kaly Hak)បានកេណ្ឌយុវជនជនជាតិចាមកុំឲ្យទៅសមរភូមិមុខ គាត់បានកេណ្ឌយុវជនជនជាតិចាម ទាំងប្រុសទាំងស្រីឲ្យរត់ចេញទៅវៀតណាម"[154] ហាក់(Hak)បានឆ្លើយថា "នៅពេលថ្នាក់លើបានដាក់ចុះនូវផែនការ ខ្ញុំមិនដែលបានអនុវត្តផែនការនោះទេ....ខ្ញុំបានញុះញង់យុវជនកុំឲ្យធ្វើទាហាន"។ គាត់បានបន្ថែមទៀតថា "គ្មានអ្នកណាម្នាក់បានដាក់បញ្ជានេះទេ វាគឺគ្រាន់តែដោយសារខ្ញុំស្អប់ខ្មៅមខ្មែរក្រហមខ្លាំងពេកប៉ុណ្ណោះ"[155]។ នេះគឺវាខុសគ្នាពីចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math) ដែលនិយាយថា "កាលី ហាក់(Kaly Hak)បានទទួលបទបញ្ជាពីខ្ញុំ [រ៉ូន ម៉ាត់(Roun Math)] ដើម្បីឲ្យធ្វើកិច្ចការទាំងនេះ"[156]។

រ៉ូន ម៉ាត់(Roun Math)ត្រូវបានពួកខ្មែរក្រហមសួរចម្លើយជាច្រើនដង ហើយសួរលំអិតច្រើនជាង ស្មាន់ ស្លេស(Sman Sleh) សា ម៉ាត់(Sa Math) ឬ ម៉ាន តិច(Man Tech)ទៅទៀត។ ចម្លើយ

---

[152] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ៊ឹម លេស(Him Leh) ខ្សែរបស់ រ៉ូន ម៉ាត់(Roun Math) ដូចបានរៀបរាប់ខាងលើ។

[153] ដូចបានរៀបរាប់រួចមកហើយ។

[154] *ចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math)* ដូចបានរៀបរាប់ខាងលើ។

[155] បទសម្ភាស៍របស់អ្នកនិពន្ធជាមួយ កាលី ហាក់(Kaly Hak) ដូចបានរៀបរាប់ខាងលើ។

[156] *ចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math)* ដូចបានរៀបរាប់ខាងលើ។

សារភាពរបស់គាត់គឺជាបុព្វហេតុនៃការចាប់ខ្លួន សា ម៉ាត់(Sa Math) ម៉ាន តិច(Man Tech) និងការតាមចាប់២៤នាក់ផ្សេងទៀតនៅលើបញ្ជីឈ្មោះដែលជាខ្មែររបស់គាត់ ដែលពួកគេទាំងនោះភាគច្រើនជាជនជាតិចាម។ ហ៊ីម លេស(Him Leh) និង លី ត្រិច(Ly Trech)ត្រូវបានចាប់ខ្លួនមុន រ៉ូន ម៉ាត់(Roun Math) ប៉ុន្តែត្រូវបានដោះលែងទៅវិញ បន្ទាប់ពីឃុំខ្លួនអស់រយៈពេលមួយឆ្នាំនៅមន្ទីរកំពង់គង់[157]។ អ្នកត្រួតពិនិត្យឯកសារ រ៉ូន ម៉ាត់(Roun Math)បានធ្វើការកត់សំគាល់នៅលើចម្លើយសារភាពរបស់គាត់ ដើម្បីតាមដាន និងចាប់ខ្លួនខ្មែររបស់គាត់។ គាត់បានគូរវង់មូលលើឈ្មោះ ឡេង សុខា(Leng Sokha) (ស្មាន់ ស្លេស(Sman Sleh)) ម៉ាត់ សិត(Math Set) និង លី ត្រេះ(Ly Treh) ហើយសរសេរថា "សមមិត្ត មែន(Men) សួរ២៦២ថាតើមនុស្សទាំងនេះនៅទីនោះឬ តាមដានពួកវា"។ អ្នកសួរចម្លើយមិនបានដឹងអំពីការចាប់ខ្លួន ស្មាន់ ស្លេស(Sman Sleh)ពីរខែមុនការចាប់ខ្លួន រ៉ូន ម៉ាត់(Roun Math)ទេ។ ក្បែរឈ្មោះ ហ៊ីម លេស(Him Leh) អ្នកត្រួតពិនិត្យបានសរសេរថា "ចាំបាច់ត្រូវពិនិត្យប្រវត្តិផ្ទាល់ខ្លួន គំនិត និងសកម្មភាពរបស់ ហ៊ីម លេស(Him Leh)ឲ្យបានច្បាស់ ដើម្បីវាយតម្លៃខ្សែរយៈនេះឲ្យបានកាន់តែច្បាស់"។ អ្នកត្រួតពិនិត្យម្នាក់ក៏បានគូសបន្ទាត់ពីក្រោមឈ្មោះ ម៉ាន តិច(Man Tech) ស្លេស លី(Sleh Ly) សា លីម(Sa Lim) សា ម៉ាត់(Sa Math) និង មីត មីន (Mit Min) ហើយក្បែរឈ្មោះទាំងនេះសរសេរថា "សមមិត្ត មែន(Men)! សរសេរលិខិតមួយច្បាប់ទៅសួរគ្រប់អង្គភាពទាំងអស់ដែលពាក់ព័ន្ធក្នុងរឿងនេះ សួរគ្រប់អង្គភាពទាំងអស់ ហើយបើសិនសួររកមិនឃើញទេ សួរ៩៩ម្តងទៀត។ សរសេរឈ្មោះប្រធានមន្ទីរ។ បើសិនអ្នកណាម្នាក់រត់គេចខ្លួនទៅណា រៀបរាប់ឲ្យលំអិតដើម្បីអាចរកពួកវាឃើញ"។ នៅចុងបញ្ចប់នៃចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math)គឺមានប្រយោគមួយសរសេរថា "ស្នើអង្គការដាក់គុកអានេះមុន"[158]។

សា ម៉ាត់(Sa Math) មិនបានសរសេរលំអិតអំពីសកម្មភាពទាំងឡាយ សរសេរត្រឹមតែថា "រ៉ូន ម៉ាត់(Roun Math) និងម៉ាន តិច(Man Tech)គឺជាមេដឹកនាំប្រឆាំងនឹង"[159]។ ម៉ាន តិច(Man Tech)មិនបានបន្សល់ទុកឯកសារអំពីកម្លាំងប្រឆាំង ឬផែនការប្រឆាំងទេ[160]។

---

[157] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ៊ីម លេស(Him Leh) ដូចបានរៀបរាប់ខាងលើ។

[158] *ចម្លើយសារភាពរបស់ រ៉ូន ម៉ាត់(Roun Math)* ដូចបានរៀបរាប់ខាងលើ។

[159] *ចម្លើយសារភាពរបស់ សា ម៉ាត់ (Sa Math)* ដូចបានរៀបរាប់ខាងលើ។

[160] *ប្រវត្តិផ្ទាល់ខ្លួនរបស់ ម៉ាន តិច(Man Tech)* ដូចបានរៀបរាប់ខាងលើ។

ចម្លើយសារភាព សា ម៉ាត់(Sa Math) និយាយថា “ក្នុងចុងខែឧសភា ឆ្នាំ១៩៧៥ នៅពេលខ្ញុំចេញដំណើរពីសាលានយោបាយនៅ កោះខ្សាច់ទន្លៀ(Koh Khsach Tonlea)[161] ខ្ញុំបាននៅអង្គភាព០៤រយៈពេល១០ថ្ងៃ ខ្ញុំបានគេចខ្លួន ហើយរត់ទៅផ្ទះ”។ គាត់ក៏បានសរសេរផងដែរថា “មនុស្សម្នាក់[162] ឈ្មោះ ស្លេស លី(Sleh Ly)បានជំរុញខ្ញុំឱ្យក្បត់បដិវត្ត” លី(Ly) បានឆ្លើយតបវិញថា៖ “ខ្ញុំមិនបានញុះញង់ឱ្យមានខ្សែប្រឆាំងទេ។ ក្នុងខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំខ្លួនឯង សា ម៉ាត់(Sa Math) ស្មាន់ ស្លេស(Sman Sleh) ឡស់ ហ៊ីម(Loh Him) ហាក់(Hak) និងម៉ាត់ សិត(Math Set)បានត្រឹមតែពិភាក្សាគ្នាអំពីការរត់ត្រឡប់ទៅផ្ទះវិញប៉ុណ្ណោះ ពីព្រោះអ្វីៗមានការលំបាកណាស់ ពួកគេឱ្យយើងហូបបបរតែបីវែកម្តងក្នុងមួយថ្ងៃប៉ុណ្ណោះ ឱ្យយើងភ្ជួរស្រែគ្មាននង្គ័ល និងឱ្យយើងលើកដី។ កន្លែងរស់នៅរបស់យើងនៅខាងលិចវត្តក្រពើហារ [ក្នុងអង្គភាព៩៩ កងវរសេនាតូច១៤២ និងកងពលធំលេខ៧០៣]។ យើងបានគេចខ្លួនចេញពីផ្ទះទៅកាន់ភូមិចាមលើ។ យើងវិលត្រឡប់មកវិញមុនពេលយើងធ្លាប់មកដល់ផ្ទះ។ យើងបានបំបែកគ្នានៅតាមផ្លូវត្រឡប់មកវិញ”[163]។

ស្មាន់ ស្លេស(Sman Sleh) រ៉ូន ម៉ាត់(Roun Math) សា ម៉ាត់(Sa Math) និងម៉ាន តិច(Man Tech) បានធ្វើទាហានខ្មែរក្រហម ពីព្រោះពួកគេត្រូវបានបង្ខំឱ្យធ្វើដូច្នេះ និងដោយហេតុថាភូមិជាច្រើននៅស្រុកកោះធំនៃខេត្តកណ្តាល ត្រូវបានត្រួតត្រាដោយពួកខ្មែរក្រហម ចាប់តាំងពីឆ្នាំ១៩៧១។ ដុលឡាស់(Dullah) បាននិយាយថា នៅក្នុងសម័យខ្មែរក្រហម យុវជនដែលបានចូលធ្វើទាហានមិនបានចូលដោយចិត្តឯងទេ។ ពួកគេត្រូវបានប្រមូលផ្តុំដោយប្រធានយុវជន យកចាប់ពីអាយុ

---

[161] “ខ្មែរក្រហមបានប្រើប្រាស់កោះទន្លៀ(Koh Tonlea)ជាជំរំអប់រំកែប្រែសម្រាប់ស្ត្រី ដែលប្តីរបស់ខ្លួនត្រូវបានគេយកទៅសម្លាប់ ឬ ត្រូវបំបែកចេញពីប្តីរបស់ខ្លួន ដោយសារការចោទប្រកាន់ថា ពួកគេជាទាហាន ឬជាកម្មករនៃរបបលន់ នល់(Lon Nol)”។ នៅក្នុងបទសម្ភាសន៍ជាមួយស្ត្រីមេម៉ាយប្រាំនាក់ ដែលត្រូវបានគេបញ្ជូនឱ្យទៅរស់នៅកោះខ្សាច់ទន្លៀ កាលីយ៉ានី(Kalyanee)បានសន្និដ្ឋានថា “បញ្ហាទាំងអស់នេះបង្ហាញឱ្យឃើញពីការប៉ុនប៉ងដាច់ខាតរបស់ពួកខ្មែរក្រហមដើម្បីបំបែកចំណងគ្រួសារ និងទំនាក់ទំនងប្រពៃណីរវាងប្តីនិងប្រពន្ធ រវាងម្តាយនិងកូនក្នុងចំណោមប្រជាជនកម្ពុជា”។ ឈ្មោះកោះមួយត្រូវបានបោះពុម្ពផ្សាយខុសនៅក្នុងអត្ថបទកាលីយ៉ានី(Kalyanee) “កោះខ្សាច់ទន្លេ”។ (កោះខ្សាច់ទន្លៀ(Koh Khsach Tonlea)គឺជាឃុំមួយរបស់ស្រុកស្អាង ខេត្តកណ្តាល)។ ម៉ាម កាលីយ៉ានី(Mam Kalyanee) “កោះខ្សាច់ទន្លៀ កោះនៃស្ត្រីមេម៉ាយ”ក្នុង*ការស្វែងរកការពិត* លេខ៤ ខែមេសា ឆ្នាំ២០០០ ទំព័រ៥៨-៦១ និងលេខ៥ ខែឧសភា ឆ្នាំ២០០០ ទំព័រ៥៥-៦០។

[162] *ចម្លើយសារភាពរបស់ សា ម៉ាត់(Sa Math)* ដូចបានរៀបរាប់ខាងលើ។

[163] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ស្លេស លី(Sleh Ly) ដូចបានរៀបរាប់ខាងលើ។

១៥ឆ្នាំឡើងទៅ...គ្មានអ្នកណាម្នាក់ស្ម័គ្រចិត្តទេ។ មានមនុស្សជាច្រើនបានបាត់ខ្លួនពីភូមិចាមលើ នៅទីនេះ ច្រើនជាង៣០នាក់តាមខ្ញុំចាំ ហើយធ្លាប់បានឃើញតែពីរ ឬបីនាក់ប៉ុណ្ណោះវិលត្រឡប់មកវិញ"[164]។

[164] បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ម៉ាត់ ឌុលឡាស់(Math Dullah) ដូចបានរៀបរាប់ខាងលើ។



អ៊ីសា ឧស្មាន់(Ysa Osman)គឺជាកូនប្រុសរបស់អ៊ីប្រាហ៊ីម អ៊ីសា(Ibrahim Ysa) និងអាម៉ាត់ សាអ៊ី ដាស់(Ahmad Sa-E-Dah)។ ឧស្មាន់(Osman)កើតនៅក្នុងឆ្នាំ១៩៧១ នៅភូមិស្វាយឃ្លាំង (ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម) ជាភូមិដែលមានការបះបោរប្រឆាំងនឹងការជិះជាន់របស់ខ្មែរក្រហមលើជនជាតិចាមម៉ូស្លីម។

ឧស្មាន់ (Osman)បានបញ្ចប់ការសិក្សានៅវិទ្យាល័យក្នុងឆ្នាំ១៩៩២។ គាត់ក៏បានសិក្សាអ៊ីស្លាមផងដែរ ហើយបានបញ្ចប់ការសិក្សា Qur-an នៅក្នុងឆ្នាំដដែលនោះដែរ។

ក្នុងឆ្នាំ១៩៩៩ ឧស្មាន់(Osman)បានចូលរួមមជ្ឈមណ្ឌលឯកសារកម្ពុជា។ គាត់គឺជាអ្នកនិពន្ធនៃអ៊ុកគូបាស់(Oukoubah) ហើយបច្ចុប្បន្នកំពុងបំពេញការងារ អំពីការប៉ះបោររបស់ជនជាតិចាមម៉ូស្លីមប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ។